ព្រះរាជាណាចក្រកម្ពុជា

ជាតិ សាសនា ព្រះមហាក្សត្រ

៣៖៧

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា

លេខ ០០១ ស.អ.យ.

រាជធានីភ្នំពេញ, ថ្ងៃទី២៥ខែ មករា ឆ្នាំ ២០១៦

# សេចក្តីជូនដំណឹង

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា សូមជម្រាបជូនដំណឹងដល់ឯកឧត្តម លោកជំទាវ លោក លោកស្រីដែលជាប្រធានមណ្ឌលថែទាំកុមារ របស់ក្រសួង ស្ថាប័ន អង្គការ សមាគម ទាំងអស់ឲ្យបានជ្រាបថា ដើម្បីអនុវត្តប្រកបដោយប្រសិទ្ធភាពនូវអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារលេខ ១១៩ អនក្រ.បក ចុះថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៥ ដែលក្រសួងបានផ្សព្វផ្សាយកាលពីថ្ងៃទី១៤ ខែធ្នូ ឆ្នាំ២០១៥ កន្លងទៅនេះ ក្រសួងស្នើសុំឲ្យឯកឧត្តម លោកជំទាវ លោក លោកស្រី បំពេញនូវទម្រង់សម្រង់ព័ត៌មានបឋមអំពីមណ្ឌលថែទាំកុមារ ដែលទម្រង់នេះបង្កើតឡើងសម្រាប់ប្រមូលព័ត៌មានបឋមស្តីពីមណ្ឌលថែទាំកុមារ របស់ឯកឧត្តម លោកជំទាវ លោក លោកស្រី ដើម្បីងាយស្រួលក្នុងការគ្រប់គ្រង ក៏ដូចជាការបញ្ចូលព័ត៌មានទៅក្នុងប្រព័ន្ធទិន្នន័យ និងកំណត់អំពីការដាក់ពាក្យស្នើសុំទទួលស្គាល់មណ្ឌលថែទាំកុមារពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

សូមបញ្ជាក់ថាមានតែមណ្ឌលដែលបានបំពេញនូវទម្រង់សម្រង់ព័ត៌មានបឋមប៉ុណ្ណោះ ដែលអាចដាក់ពាក្យស្នើសុំដំណើរការមណ្ឌលថែទាំកុមារពីក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។

អាស្រ័យហេតុនេះ សូមឯកឧត្តម លោកជំទាវ លោក លោកស្រីមេត្តាសហការ និងបំពេញទម្រង់សម្រង់ពត៌មានបឋមដូចមានភ្ជាប់មកជាមួយ ហើយផ្ញើទៅមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី ខេត្ត ដែលមណ្ឌលស្ថិតនៅ ឬមកកាន់នាយកដ្ឋានសុខុមាលភាពកុមារ នៃក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា (តាមរយៈអ៊ីម៉ែល mosvy.cwd@gmail.com ឬ srychandina@gmail.com ឲ្យបានមុនថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០១៦។ សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទងតាមរយៈទូរសព្ទលេខ 023 214 039 រៀងរាល់ម៉ោងធ្វើការ។ ចំពោះទម្រង់សម្រង់ព័ត៌មានបឋមអាចរកបាននៅក្នុងគេហទំព័រក្រសួង www.mosvy.gov.kh។

ក្រសួងសង្ឃឹមថា ឯកឧត្តម លោកជំទាវ លោក លោកស្រីនឹងចូលរួមសហការអនុវត្តតាមស្មារតីអនុក្រឹត្យរបស់រាជរដ្ឋាភិបាលឲ្យទទួលបានជោគជ័យជាមិនខាន។

សូមភ្ជាប់មកជាមួយនូវ:

- ទម្រង់សម្រង់ព័ត៌មានបឋម (០១ច្បាប់)
- ច្បាប់ចម្លងអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ (០១ច្បាប់)
- ការប្តេជ្ញាចិត្តរបស់ក្រសួងក្នុងការអនុវត្តអនុក្រឹត្យស្តីពីការគ្រប់គ្រងមណ្ឌលថែទាំកុមារ (០១ច្បាប់)

រដ្ឋមន្ត្រី

វង សូត